**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ដំណោះស្រាយលើការទាមទាររបស់បងប្អូនអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យា

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យាដែលជាដៃគូសហការរបស់ក្រុមហ៊ុន PASSAPP, GRAB, WOWNOW, TADA, TAXI MAXIM, MOVE, THIDA ANGKOR និងក្រុមហ៊ុនផ្សេងៗទៀត មេត្តាជ្រាបថា បន្ទាប់ពីទទួលសំណើរបស់បងប្អូនអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យា ក្រសួងបានបើកកិច្ចប្រជុំ និងបានសម្របសម្រួលដោះស្រាយដោយយកចិត្តទុកដាក់ ដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

១.តំណាងក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនអ្នកដំណើរ និងតំណាងអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យាបានឯកភាពគ្នាលើការដំឡើងតម្លៃដឹកជញ្ជូនចំនួន ៥០០រៀល ក្នុងមួយជើងដំណើរ ទៅលើតម្លៃអនុវត្តបច្ចុប្បន្នជាបណ្តោះអាសន្នក្នុងរយៈពេល ៣ខែ ចាប់ពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦ ដោយតម្លៃបន្ថែមនេះគឺផ្តល់ជូនអ្នកបើកបរដោយមិនរាប់បញ្ចូលការកាត់កម្រៃជើងសារឡើយ។

២.ចំពោះការបិទគណនី ឬការប្រព្រឹត្តិកំហុសរបស់អ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យាដែលជាដៃគូសហការ ក្រុមហ៊ុនត្រូវមាននីតិវិធីអនុវត្តជាក់លាក់ ដោយត្រូវផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់ និងជូនដំណឹងមុនជាចាំបាច់។

៣.តំណាងក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនអ្នកដំណើរបានឯកភាពកាត់កម្រៃជើងសារមិនឱ្យលើសពី ១៥ភាគរយ ក្នុងមួយជើងដំណើរ។

តំណាងក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនអ្នកដំណើរ និងតំណាងអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យាបានឯកភាពចូលរួមបញ្ចៀសរាល់បញ្ហាប្រឈមដែលអាចកើតមានឡើងនាពេលខាងមុខ និងសហការចូលរួមដោះស្រាយនៅគ្រប់យន្តការរបស់ក្រសួងដោយសន្តិវិធី។

អាស្រ័យហេតុនេះ សូមសាធារណជន ជាពិសេសបងប្អូនអ្នកដឹកជញ្ជូនតាមថ្នាលបច្ចេកវិទ្យា មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្ត។

ថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦